ម៉ាចប្រហែលជាទើបនឹងដឹងថា លើកនេះខ្ញុំផ្ដើមឈរខាងសាមីន មិនត្រឹមតែ នៅក្នុងការលែងលះវាចោលទេ ថែមទាំងមិនឱ្យវាមួយសេនណាទាំងអស់។

មនុស្សស្រីជាទីស្រលាញ់នៅក្នុងបេះដូងខ្ញុំ ហាក់សប្បាយចិត្តជាខ្លាំង។ នាងបែរមកស្វាគមន៍ខ្ញុំដូចរាល់ដង ដែលតែងតែបញ្ចេញនូវស្នាមញញឹមរបស់នាងដែលទុកសម្រាប់តែខ្ញុំម្នាក់គត់។

ខ្ញុំងាកទៅចង្អុលនាង៖

«ឯងក៏អ៊ីចឹងសាមីន! បើឯងមិនព្យាបាលខ្លួនឯង មិនធ្វើខ្លួនត្រឹមត្រូវត្រៀមវះកាត់ ហើយលេងល្បិចជាមួយគ្រូពេទ្យទៀតនោះ បងនឹងបាត់មុខទៅ មិនឱ្យឯងឃើញទៀតទេ!»

មិនយូរប៉ុន្មាន ការវះកាត់បានចូលមកដល់។ ពួកយើងទាំងពីរត្រូវបានគេបញ្ជូនទៅកាន់បរទេស កន្លែងដែលមានអាទិភាព និងឧបករណ៍គ្រប់គ្រាន់ សេវាកម្ម កម្រិតស្តង់ដារតាមដែលនាងចង់បាន។

ការវះកាត់នឹងចូលកៀកមកដល់ហើយ។ នេះជាអ្វីដែលធ្វើឱ្យខ្ញុំមានអំណរ ក៏ជាអ្វីដែលធ្វើឱ្យខ្ញុំគិតថាកំពុងតែផ្លាស់ប្ដូរជីវិតយើងទាំងពីរ ដោយផ្នែកមួយនៃរាងកាយរបស់ខ្ញុំនឹងប្ដូរទៅនៅជាមួយនាង អស់មួយជីវិតដែលនៅសល់។ ខ្ញុំមិនដែលសោកស្ដាយនោះទេ។

ម៉ាចនិងគេ មិនបានលែងលះនោះទេ ប៉ុន្តែប្ដីនាងលែងមកកាន់មន្ទីរពេទ្យតាំងពីកន្លះខែមុនដែលយើងត្រៀមមកវះកាត់នេះម្ល៉េះ ដោយសារមកពេលណា នាងមិននិយាយរក ហើយបើទោះជានិយាយក៏មានតែពាក្យទាស់ទែងគ្នានិងការទាមទារលែងលះគ្នា។

ប្រហែលជាដឹងថា អ្វីៗមិនអាចត្រឡប់ទៅប្រសើរឡើងដោយការជួបមុខ ម៉ាចបានរៀបចំគម្រោងធ្វើអ៊ីចឹងដាក់សាមីនសិន ឱ្យនាងបានស្ងប់ចិត្តនៅក្នុងការទទួលយកការវះកាត់ ក្រោយពីនោះគេគង់តែនឹងរកវិធីថ្មីៗទៀតទៅតាមចរិតលក្ខណៈរបស់គេ។ ខ្ញុំមិនខ្វល់ជាមួយទេ!

ឥឡូវនេះ ពេលវេលាវះកាត់បានឈានចូលមកដល់ហើយ ខ្ញុំត្រូវបានគេបញ្ជូនមកក្នុងបរិវេណបន្ទប់ដ៏សែនទំនើបមួយ ឧបករណ៍គ្រប់យ៉ាង គឺពិតជាស្វ័យប្រវត្តិលើសពីអ្វីដែលខ្ញុំបានស្មានទុកជាមួយបច្ចេកវិទ្យាកំពូលៗចុងក្រោយបង្អស់។

វេជ្ជបណ្ឌិតដាក់ខ្ញុំគេងទៅលើគ្រែនោះ ទាំងបណ្តាអំពូលភ្លើងនៅពីលើក្បាលខ្ញុំ មិនទាន់បើកឡើងនៅឡើយ។ ទោះយ៉ាងណា  សភាពភាពភ្លឺចិញ្ចាចមួយ បានជះចាំងក្នុងប្រអប់បេះដូងរបស់ខ្ញុំរួចទៅហើយ ជាមួយសំណួរជាច្រើនដែលបានរត់ចេញចូលជជែកជាមួយខ្ញុំនៅក្នុងទស្សនៈខ្ញុំខ្លួនឯងថា ចាំអីទៀត? ម៉ាច មិនបានរក្សាសន្យាមុន! វានិយាយថានឹងថែទាំនាង ប៉ុន្តែពីរឆ្នាំជាងសោះនេះ វាធ្វើឱ្យ

នាងឈឺធ្ងន់ស្ទើរតែបាត់បង់ជីវិត ដោយសារការគេងកើតទុក្ខរីងរៃ។ វាហ៊ានមានប្រពន្ធចុងនៅខាងក្រៅ មានស្រីរាប់ផ្លូន ហើយចុងក្រោយ វាគិតអំពីរឿងកេរមរតកដដែលជាដដែល។

មនុស្សប្រុសម្នាក់ ដែលគ្មានជំនឿលើគុណធម៌និងគុណតម្លៃរបស់ខ្លួនឯង ហេតុអីកាលណោះខ្ញុំយល់ព្រមស្លុង ជឿសម្ដី ហើយប្រគល់មនុស្សស្រីជាទីស្រលាញ់របស់ខ្ញុំទៅឱ្យវា ទាំងដែលអាមីនពិតជានៅត្រូវការខ្ញុំយ៉ាងខ្លាំង។

ហេតុអីខ្ញុំមើលទៅខ្លួនឯងថា ជាមនុស្សអន់ខ្សោយម្នាក់ ដែលមិនសមនឹងឈរផ្ទឹមជាមួយនាង ព្រោះតែពាក្យញុះញង់បន្តុះបង្អាប់របស់វា?

ធ្វើស្នូរជើងមនុស្សជាច្រើនបានដើរចូលមកដល់។ រូបរាងគ្រូពេទ្យពាក់អាវស ជាឯកសណ្ឋានដែលពួកគេនឹងផ្លាស់ប្ដូររាងកាយរបស់ខ្ញុំ សរីរាង្គរបស់ខ្ញុំទៅឱ្យនាងនៅពេលបន្តិចទៀតនេះ។ គ្រូពេទ្យចូលមកប្រាំនាក់គត់គឺល្មមនឹងព័ទ្ធជុំវិញគ្រែខ្ញុំទៅហើយ ខ្ញុំគិតថា នេះមិនមែនជាការវះកាត់ធម្មតានោះទេ។

សូមព្រះជាម្ចាស់ប្រទានពរដល់យើងទាំងពីរ!

នេះគឺជាការអធិដ្ឋានរបស់ពួកយើងតាមការយល់ដឹងតាំងពីតូច ដែលខ្ញុំជាអ្នកបបួលនាងឱ្យចូលគ្រិស្តសាសនា ដោយសារនៅទីនោះនឹងធ្វើឱ្យចិត្តនាងបានភ្លឺស្វាង អាចយកឈ្នះលើពាក្យជេរប្រទេច មជ្ឈដ្ឋានជុំវិញខ្លួននាង នាងអាចយកឈ្នះនូវពាក្យតំនៀលថា កូនគ្មានម៉ែឪ កូនត្រូវបានគេលក់ កូនគេយកមកចិញ្ចឹមធ្វើជាអ្នកបម្រើ។ល។

«អ្វីៗល្អទាំងអស់»

ពេទ្យកំពុងនិយាយគ្នារឿងសុខភាពខ្ញុំជាភាសាអង់គ្លេស ខ្ញុំដឹងច្បាស់។ ខ្ញុំបានត្រូវដៃពេទ្យម្នាក់ដែលមានពាក់ស្រោមផង ចាប់ត្រង់ស្មាតិចៗ។

នេះជាសញ្ញាលួងលោម ដែលគ្រប់គ្នាក្នុងផ្នែកវេជ្ជសាស្ត្របានផ្ដល់មកឱ្យខ្ញុំ តាំងតែពីស្រុកខ្មែរមកដល់ទីនេះ មិនថាស្នាមញញឹម ជាបាតដៃ ជាការគោះស្មា ខ្ញុំជាHeroសម្រាប់នាង។

ដោយហេតុផលអ្វីក៏ដោយខ្ញុំមានមោទកភាពចំពោះខ្លួនឯង ដែលមានសេចក្ដីក្លាហានពេញទំហឹងចំពោះការបរិច្ចាគដោយមិនចង់បានអ្វីត្រឡប់ទាំងអស់។

«នាងយ៉ាងម៉េចហើយ?!»

ខ្ញុំសូមសួរគាត់តិចៗធ្វើឱ្យគាត់បង្ហាញកែវភ្នែកហួសចិត្តពីលើម៉ាសនិងរបាំងមុខដែលសម្លឹងមកខ្ញុំដោយអាណិតអាសូរ។

បុរសនេះពន្យល់មកខ្ញុំ៖

«ពេលនេះហើយ គិតអ្នកណាទៀត? គិតខ្លួនឯងសិន! ប្រតិបត្តិការនេះនឹងចំណាយពេលប្រហែល ៤ម៉ោង លើសខ្វះតិចតួចតាមជាក់ស្តែង! នៅពេលរួចរាល់ភ្លាមៗមុខរបួសនឹងរើឈឺចាប់ ប៉ុន្តែចាំណ៎ា គួរតែព្យាយាមក្រោកចេញពីគ្រែ ឱ្យបានតាំងពីថ្ងៃដំបូង ហើយសំងំក្នុងផ្ទះឱ្យបានហោចណាស់រយៈពេលមួយសប្តាហ៍។»

«ចុះគេ? អ្នកដែលទទួលក្រលៀនពីខ្ញុំ?!»

សាជាថ្មី ខ្ញុំនៅតែគិតអំពីគេ។ ទឹកមុខស្គមខ្វងរបស់គេនៅតែអណ្តែតមកក្នុងការចងចាំរបស់ខ្ញុំ។ ប្រហែលមកពីធុញដែលខ្ញុំ ចង់ដឹងពេក ឬអាណិតស្នេហាស្មោះរបស់ខ្ញុំទេ គាត់ក៏បង្ខំចិត្តប្រាប់ថែមប៉ុន្មានម៉ាត់ទៀត៖

«ក្រលៀនដែលយកចេញពីម្ចាស់ជំនួយដែលកំពុងមានជីវិត នឹងធ្វើការយ៉ាងលឿនណាស់ ឈប់ព្រួយទៅមួយអាទិត្យ ឬ១០ថ្ងៃអីហ្នឹងនាងនឹងធម្មតាវិញហើយ! បានហើយ មិនមែនពេលសួរនាំទេ! បិទភ្នែកសំងំសម្រាកទៅ»

ខ្ញុំចាប់ផ្តើមមានអារម្មណ៍ខ្សោយនៅលើថ្ងាស ទ្រូង រហូតដល់ចុងជើង ដែលខ្ញុំដឹងថា ចាំបាច់ត្រូវដល់ពេល ដេកសម្រាកហើយ។

«នឹងនរចិត្តណ៎ា គ្រប់យ៉ាងនឹងល្អ! សូមរក្សាភាពស្ងប់ស្ងៀមកុំគិតច្រើន កុំភ័យ កុំខ្វល់ខ្វាយ!»

នេះជាពាក្យចុងក្រោយពីវេជ្ជបណ្ឌិតបរទេសដែលខ្ញុំបានឮ។ ពួកគេលែងនិយាយនឹងខ្ញុំទៀត ដោយចុចកុងតាក់បើកភ្លើងពីលើខ្ញុំចិញ្ចាច ដូចជាបង្ខំឱ្យខ្ញុំបិទភ្នែកយកតែម្តង។

ខ្ញុំចាប់ផ្តើមមានអារម្មណ៍ឈឺក្បាលទាំងដែលពេទ្យមិនទាន់ចាក់ថ្នាំសន្លប់ឱ្យ។ ប៉ុន្តែមិនដឹងយ៉ាងម៉េចបានជាក្រោយមក ខ្ញុំមានអារម្មណ៍ថា ការរង់ចាំទទួលម្ចុលថ្នាំរបស់ខ្ញុំ ដូចជាយូរម្ល៉េះ?

នៅពេលត្រចៀកខ្ញុំផ្ទង់តាមដាន ខ្ញុំទទួលដឹងថា សម្រិបជើងឆ្លេឆ្លានិងអ្វីៗមិនប្រក្រតីបានកើតឡើង។ គ្រូពេទ្យបរទេសគ្រប់គ្នាហាក់មិនព្រមធ្វើការរបស់ពួកគេ បែរជាដើរចច្រប់ចុះឡើង ឡើងចុះ ចច្រប់ជុំវិញខ្លួនខ្ញុំ។

ទោះបីជាពួកគេព្យាយាមមិនបញ្ចេញសំឡេងឮដល់ខ្ញុំក៏ដោយ ក៏សំឡេងខ្សឹបខ្សៀវ ឬកេះគ្នាជាប្រផ្នូលមិនល្អមួយ។

រហូតដល់ពេលដែលស្នូរទូរស័ព្ទរោទ៍មួយរឹងទ្បើង បានកាត់ផ្ដាច់ចោលរាល់ការសង្ស័យនិងអារម្មណ៍រង់ចាំអន្ទះសាររបស់ខ្ញុំទាំងអស់ ព្រោះខ្ញុំសម្រេចចិត្តថា បើកភ្នែកទ្បើងមកវិញ។

ពួកគេចាកចេញពីគ្រែខ្ញុំ ហើយនាំគ្នាទៅឈរព័ទ្ធជុំវិញអ្នកលើកទូរសព្ទ។

ចុងក្រោយ ម្នាក់ក្នុងចំណោមពួកគេងាកមុខមកសម្លឹងខ្ញុំ ដែលក្រសៃភ្នែកនោះចម្លែកពេកពន់ ធ្វើឱ្យអ្នកផ្សេងទៀតក៏ងាកមកមើលខ្ញុំបន្តបន្ទាប់ ខ្លះទៀតក៏ឱនសម្លឹងឥដ្ឋ។

អ្វីមួយយ៉ាងធំ គឺធ្ងន់ជាងបណ្ដាអំពូលភ្លើងទាំងឡាយដែលច្រាស់ច្រាល់អានុភាពមកលើរូបរាងកាយខ្ញុំនេះទៅទៀត បាននឹងកំពុងធ្លាក់សង្កត់មកលើរាងកាយរបស់ខ្ញុំ។

«មានរឿងអី?»

ខ្ញុំសួរពួកគេភ្លាមៗដោយបបូរមាត់ខ្ញុំចេះញ័រទទ្រើក បេះដូងខ្ញុំហាក់មានចម្លើយសម្រាប់ខ្លួនឯង ដែលមិនមែនចម្លើយល្អនោះទេ។ ហេតុអ្វីបេះដូងខ្ញុំចេះភ័យ លោតញាប់មិនធ្លាប់មានសោះក្នុងឆាកជីវិត?

គឺពេលនោះហើយដែលខ្ញុំបានទទួលដំណឹងថា ខ្ញុំមិនបាច់ចាំវះកាត់ទេ ព្រោះខ្ញុំបានបាត់បង់សាមីនជាស្ថាពរទៅហើយ។ សាមីនបានស្លាប់នៅពេលដែលត្រៀមរៀបចំទទួលយកសរីរាង្គខ្ញុំ ពេលត្រៀមរៀបចំវះកាត់បរិច្ចាគទៅឱ្យនាង។

ពេទ្យប្រាប់ពីដំបូងថា នាងមានឆ្លងរោគ ហើយក្ដៅខ្លួនជួយមិនទាន់ តែក្រោយមកទៀត មានពាក្យខ្សឹបខ្សៀវថានាងមានចេតនានៅក្នុងការធ្វើអត្តឃាត តាមរយៈការលួចយកថ្នាំមួយចំនួនរបស់ពេទ្យមកលេបនៅមុនពេលវេលាធ្វើដំណើរមកកាន់ទីនេះ។

ខ្ញុំមិនអស់ចិត្តចំពោះរឿងទាំងអស់នោះទេ។

គ្រប់យ៉ាងហាក់ដូចជាសុបិនសម្រាប់ខ្ញុំ។ ខ្ញុំគិតហើយគិតទៀត នៅតែមិនយល់សោះថា ហេតុអីបានជាវាលឿនម្ល៉េះ?

ហេតុអីម្រាមដៃនាង ចាប់ដៃខ្ញុំនៅថ្ងៃនោះ បានក្លាយជាការចាប់ដៃចុងក្រោយបង្អស់?

នៅព្រះវិហារ យើងតែងនិយមអានបណ្ដាពាក្យទូន្មានល្បីៗរបស់ពីភពលោក។ ពាក្យមួយរបស់ Lauren Klarfeld ដែលខ្ញុំតែងចងចាំជាប់ជានិច្ច គឺថា មនុស្សគ្រប់គ្នាគ្រាន់តែជាភ្ញៀវនៅក្នុងរឿង

និទានរបស់យើង ជាទស្សនិកជន ឬអ្នកចូលរួមសម្តែងនៅក្នុងល្ខោនជីវិតយើងតែប៉ុណ្ណោះ ចប់ធុរៈ ពួកគេនឹងចាកចេញទៅ។ ប៉ុន្តែសាមីន បានសន្យាជាមួយខ្ញុំរួចហើយថា នឹងសាងជីវិតថ្មីឡើងវិញ នាងថានឹងជាសះ ដើម្បីមករស់នៅជិតខ្ញុំ ព្រោះសាមីនបានដឹងខ្លួនឯងថា ប្រសិនជានាងស្លាប់ នាងនឹងបែកពីខ្ញុំជារៀងរហូតហើយ ចុះហេតុអ្វីនាងនៅតែរើសយកផ្លូវមួយនេះ?

នៅពេលមនុស្សជាទីស្នេហារបស់យើង ត្រូវក្លាយមកត្រឹមជាការចងចាំ ការចងចាំទាំងនោះគឺជាកំណប់ទ្រព្យមួយដែលគាស់ឡើងមកវិញមិនបានជារៀងរហូត ហើយវាជាសេចក្តីសុខឯកសិទ្ធិដ៏ឈឺចាប់មួយ។

ប៉ុន្មានខែក្រោយ ខ្ញុំក៏បានទទួលនូវសំបុត្រសម្ងាត់ដែលនាងបានសរសេរផ្ញើមកឱ្យខ្ញុំក្នុង MAIL។

«ខ្ញុំមិនចង់យកអ្វីពីបងទៀតនោះទេបងម៉ឺន! ខ្ញុំបានយកអ្វីៗសឹងគ្រប់យ៉ាងពីបងហើយក្នុងជាតិនេះ មិនថាពេលវេលា និងការអត់ធន់ ការលះបង់របស់បង ខ្ញុំបានធ្វើឱ្យបងទ្រាំរស់នៅដោយម្នាក់ឯងឯកោ និងលំបាកលំបិន! ខ្ញុំដឹងថា រវាងពួកយើង អ្វីៗកាលពីអតីតកាលមិនអាចវិលមកត្រឡប់ក្រោយបានទៀតនោះទេ ខ្ញុំមិនមែនសាមីនដូចពីមុនឡើយ ជាតិនេះខ្ញុំមិនអាចមានកូនបាន ថែមទាំងពិបាកនឹងមានជីវភាពជាប្តីប្រពន្ធដែរ! ខ្ញុំមានជំងឺច្រើនមុខ ហើយខ្ញុំគិតថា បើលើកនេះខ្ញុំបែងចែកក្រលៀនជាមួយបង ហើយប្រសិនបើរាងកាយរបស់ខ្ញុំព្យាយាមបដិសេធក្រលៀនថ្មីនោះ ខ្ញុំនឹងមានវិប្បដិសារៈ។ ពេទ្យប្រាប់ខ្ញុំច្បាស់ហើយថា ភាគរយច្រើនណាស់ដែលមនុស្សបានដោះដូរក្រលៀនរួច តែមិនដំណើរការល្អតាមការគ្រោងទុកនោះ! ឱកាសនៃការបដិសេធរបស់រាងកាយខ្ញុំចំពោះសរីរាង្គថ្មី គឺមានភាគរយច្រើនបំផុតបើយោងតាមសភាពជំងឺនានារបស់ខ្ញុំ។ ខ្ញុំហត់ណាស់បងម៉ឺន! ខ្ញុំហត់ខ្លាំងណាស់នៅក្នុងការរស់នៅ លើគ្រែពេទ្យមួយរយៈកន្លងមក ហើយការដោះដូរក្រលៀននឹងធ្វើឱ្យខ្ញុំរស់នៅបែបនេះយូរជាងនេះតទៅទៀត។ ពិសេស ខ្ញុំមិនចង់ឃើញមុខបងដើរចុះឡើងជុំវិញមន្ទីរពេទ្យព្រោះតែខ្ញុំ នៅខណៈដែលខ្ញុំមិនអាចឱបបងហើយនិងរស់នៅជាមួយបង ឬសូម្បីតែមានកម្លាំងចិត្តនឹងសើចដាក់បងនោះទេ! ការចាកចេញនៅពេលនេះ ប្រសើរជាងនៅពេលដែលយើងត្រូវបាត់បង់អ្វីៗច្រើនជាងនេះ! បងតែងបង្រៀនទូន្មានខ្ញុំមិនឱ្យត្រាំត្រែងសោកស្តាយនូវអ្វីដែលកន្លងហួស បងថា គ្រប់យ៉ាងតែងអាចចាប់ផ្តើមសាជាថ្មី តែខ្ញុំនៅតែលួចស្តាយ បើសិនជាអាចជ្រើសរើសបានខ្ញុំសុំឱ្យពីរនាក់ យើងធំឡើងនៅក្នុងមជ្ឈមណ្ឌលនោះជាមួយគ្នា មិនទៅជាមួយប៉ា ពេលនោះបងនឹងមិនជឿតាមគេដែលថាបងមិនស័ក្តិសមជាមួយខ្ញុំ ហើយទៅទ្រាំរស់នៅឆ្ងាយពីខ្ញុំរបៀបនេះទេ! វាឈឺចាប់ណាស់ឈឺខ្លាំង បងដឹងដែរអត់? ប្រសិនបើខ្ញុំនៅតែជាក្មេងមណ្ឌល ឬក្មេងជើងចាប ប្រហែលជាយើងបានក្លាយជាប្តីប្រពន្ធនឹងគ្នាយូរណាស់មកហើយ។ សន្យានឹងខ្ញុំថា បងត្រូវរស់នៅជាខ្លួនឯង

រហូតតទៅ សាងប្រយោជន៍ជួយដល់ក្មេងកំព្រាដទៃទៀតដូចដែលបងតែងតែដាស់តឿនខ្ញុំឱ្យធ្វើ! ជាតិនេះខ្ញុំជាមនុស្សទន់ខ្សោយ មិនអាចទ្រាំទ្របានជាមួយនឹងសភាពជំងឺរបស់ខ្លួនឯងផង ខ្ញុំជួយពីណាបាន? ខ្ញុំស្អប់អ្វីៗដែលមិនពិតជុំវិញខ្លួន ខ្ញុំស្អប់អ្វីៗដែលជាល្បិចកល ហើយខ្ញុំស្អប់មនុស្សដែលកុហកបោកបញ្ឆោត ទ្រុស្តមនុស្សដូចគ្នា រាល់ទិវារាត្រីខ្ញុំត្រូវនៅក្បែរមនុស្សដែលខ្ញុំស្អប់ឡើងៗ ជីវិតខ្ញុំគ្មានការស្រលាញ់ផងតើខ្ញុំផ្តល់ការស្រលាញ់ឱ្យទៅអ្នកណាបាន? ប៉ុន្មានឆ្នាំមកនេះ អារម្មណ៍ដ៏មានសុវត្ថិភាពនៃបណ្តាថ្ងៃដែលខ្ញុំមានបង បានបាត់បង់សឹករេចរឹលទៅជាលំដាប់ ខ្ញុំជាមនុស្សស្រីដ៏អស់សង្ឃឹមម្នាក់ ដែលបានត្រឹមដេកនឹកបុរសម្នាក់ដែលខ្ញុំតែងតែស្រលាញ់ជាទីបំផុតនៅក្នុងជីវិតនេះ! អរគុណដែលបង្រៀនខ្ញុំឱ្យចេះញញឹមនៅពេលដែលខ្ញុំមិនធ្លាប់ជឿថា ជាតិនេះខ្ញុំអាចញញឹមចេញមកបាននោះឡើយ! ខ្ញុំសូមអរគុណចំពោះបណ្តាសម្តីចេញពីចិត្ត សូមអរគុណចំពោះបេះដូងពេញដោយសម្រស់នៃអំពើល្អទាំងអស់ដែលបងបានផ្តល់មកឱ្យខ្ញុំ  នៅជីវិតចុងក្រោយរបស់ខ្ញុំ បងនៅតែមិនបោះបង់ខ្ញុំមកនៅក្បែរៗខ្ញុំ លះបង់ដើម្បីខ្ញុំ! ខ្ញុំស្រលាញ់បងណាស់ ហើយខ្ញុំនឹងស្រលាញ់បងជារៀងរហូតតទៅ!»

ខ្ញុំមិនដឹងថា ទឹកភ្នែករបស់ខ្ញុំបានស្រក់អស់ប៉ុន្មានហើយនោះទេ គឺជាពេលដែលខ្ញុំអានលិខិតរបស់នាងដោយភាពស្ងៀមស្ងាត់ ប៉ុន្តែបេះដូងរបស់ខ្ញុំដេកស្លាប់បាត់ទៅតាមបណ្តាតួអក្សរទាំងឡាយនោះដែលរហោស្ថានជាងសភាពរាងកាយខ្ញុំទៅទៀត។

បេះដូងរបស់ខ្ញុំលែងមានប្រតិកម្ម ព្រោះទំហំនៃសេចក្តីឈឺចាប់នៅពេលនេះមិនអាចធ្វើឱ្យខ្ញុំនិយាយចេញ ឬក៏ស្រែកបាន។ ខ្ញុំល្ងង់ខ្លាំងណាស់ បានជាមើលមិនដឹងថា អាមីនមានវិបត្តិផ្លូវចិត្ត និងបញ្ហាធ្លាក់ទឹកចិត្តជាយូរមកហើយ។ ខ្ញុំមិនដឹងថា ភាពឯកោនៅក្នុងផ្នត់គំនិតរបស់នាងតាំងពីកំណើតដែលនាងត្រូវបានគេបោះបង់ចោលហើយរស់នៅដូចជាទាសករ ហើយការបង្ហាញខ្លួនរបស់ខ្ញុំ ធ្វើឱ្យខ្ញុំក្លាយជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតសម្រាប់នាង ឱ្យនាងមើលរំលងនូវឱកាសផ្សេងៗទៀតមិនថាការរៀបចំអាជីព ការប្រើប្រាស់លុយកាក់ ឬក៏ការរីករាយជាមួយនឹងជីវិតតាមបែបថ្មី  នាងគិតតែម្យ៉ាងគឺ បើសិនជាមិនបានជួបខ្ញុំជីវិតរបស់នាងនឹងគ្មានន័យអ្វីទាំងអស់។

ខ្ញុំយល់ច្រឡំថា ការប្រគល់មនុស្សម្នាក់ឱ្យទៅមនុស្សម្នាក់ទៀតថែរក្សាជំនួសយើង ថាជាការផ្តល់នូវសុភមង្គលឱ្យគេ។

ការធ្វើអត្តឃាតរបស់សាមីន ទោះនោះជាការសម្រេចផ្ទាល់ខ្លួនរបស់នាង ប៉ុន្តែវាផ្តើមចេញពីអាកប្បកិរិយារបស់ខ្ញុំ ដែលធ្វើអ្វីៗស្រេចតែចិត្តខ្លួនឯងហើយមិនបានគិតពីអារម្មណ៍របស់ភាគីពាក់ព័ន្ធ។ ការខកចិត្ត និងថប់បារម្ភនេះ នាងបានទម្លាក់ខ្លួនឯង អោយរាំរ៉ៃទៅក្នុងភាពអស់សង្ឃឹម សូម្បីតែចុង

ក្រោយខ្ញុំបានផ្តល់សង្ឃឹមឱ្យនាង ដើរមកនៅក្បែរខ្លួននាងវិញហើយ ប៉ុន្តែវាយឺតពេលព្រោះនាង គ្មានទំនុកចិត្តនោះទេ នាងគ្មានសូម្បីតែទំនុកចិត្តថាអ្វីៗនឹងអាចល្អឡើងវិញ គ្មានទំនុកចិត្តសូម្បីតែថារាងកាយរបស់នាងនឹងអាចមានលទ្ធភាពក្នុងការទទួលយកការបរិច្ចាគរបស់ខ្ញុំ ឬមករស់នៅជាប្រពន្ធខ្ញុំ។

ក្រៅពីនោះនាងបានបន្សល់ទុកនូវមរតកទាំងអស់ពីឪពុករបស់នាង គឺបុរសចំណាស់ម្នាក់ដែលខ្ញុំធ្លាប់ជួយសង្គ្រោះនៅក្បែររបងមជ្ឈមណ្ឌលកុមារកំព្រាកាលពីច្រើនឆ្នាំមុន ឱ្យមកខ្ញុំតែម្នាក់គត់។

ម៉ាចបានត្រឹមទទួល សិទ្ធិរស់នៅលើផ្ទះដែលប្តីប្រពន្ធគេបានទិញឡើងជាមួយគ្នានោះ ហើយខ្ញុំជាអ្នកគ្រប់គ្រងលើអ្វីៗទាំងអស់របស់នាងនិងឪពុករបស់នាង។ ម៉ាចបានរកគ្រប់វិធីប្រឆាំងតាមផ្លូវច្បាប់នឹងបណ្តឹមរតកនោះ រួមទាំងរកមេធាវី រកក្រុមពេទ្យមកបញ្ជាក់ថា នាងមានជំងឺវិកលឆ្កួតវង្វេងបានជាធ្វើការផ្ទេរកម្មសិទ្ធិទាំងអស់ទាំងនោះ មកឱ្យខ្ញុំ។ មិនថាចោទភរិយាខ្លួនឯងថាឆ្កួត ឬមានសាហាយ វាបានធ្វើគ្រប់យ៉ាងទាំងអស់ដោយឃុបឃិត នឹងអ្នកច្បាប់ដែលស្រលាញ់លុយជាងយុត្តិធម៌។ សំណាងល្អ ខ្ញុំមានស្គាល់មេធាវីសប្បុរសធម៌ខ្លះ ដែលបានមកជួយពេញដៃជើងលើទំនាស់ផ្នែកច្បាប់នេះ។

ចុងក្រោយ បន្ទាប់ពីអំពើទុរយស លោភលន់ក្រហល់ក្រហាយជាបន្តបន្ទាប់ ម៉ាចមិនបានឈ្នះក្តីទេ។

សម្រាប់ខ្ញុំ សាមីនមិនបានឆ្កួត វិកលអ្វីទាំងអស់ ។ នាងនៅតែជានារីម្នាក់ដែលមានដួងចិត្តសប្បុរស ទុកចិត្តថាអ្នកដទៃនឹងល្អដូចខ្លួន ទីបំផុតនាងខកចិត្តឡើងៗនៅពេលដឹងថាម៉ាចកុហកនិងក្បត់ចិត្ត។ ដ្បិតតែនាងមានប្រាជ្ញាតិច មានរាងកាយខ្សោះខ្សោយ និងមានការភ័យខ្លាចតាំងពីវ័យកុមារ តែនាងនៅតែជាមនុស្សដែលមានចិត្តកក់ក្តៅ ចិត្តល្អចំពោះអ្នកដទៃ បានជានាងមិនដាច់ចិត្តកាត់យកសរីរាង្គពីខ្ញុំ។ នោះគឺជាឧត្តមគតិដែលមនុស្សទន់ខ្សោយដូចនាងមាន លុះថ្ងៃស្លាប់ឯមនុស្សជាច្រើនទៀតដែលគិតថាខ្លួនឯងរឹងមាំ ឆ្លាតវៃបែរជាអាត្មានិយមនិងបាត់បង់គុណតម្លៃស្មើសូន្យ។

តាមពិតបញ្ហាសុខភាពផ្លូវចិត្ត ដូចជាការថប់បារម្ភ និងការធ្លាក់ទឹកចិត្តរបស់សាមីនបានបណ្តាលឱ្យនាងបន្តមានជំងឺរ៉ាំរ៉ៃជាច្រើន តែប្រសិនខ្ញុំមិនបោះបង់នាងចោល នាងនឹងមិនធ្លាក់ខ្លួនដល់សភាពអស់សង្ឃឹមមួយនេះឡើយ។

ដើម្បីបញ្ជាក់និងចងចាំនូវភាពបរិសុទ្ធនៅក្នុងបេះដូងនាង ខ្ញុំបានបង្កើតនូវមជ្ឈមណ្ឌលថ្មីមួយនៅលើកន្លែងចាស់ ភូមិជើងចាប ដាក់ឈ្មោះថា«ក្តីសង្ឃឹមរបស់សាមីន» ហើយខ្ញុំបានជួយឱ្យក្មេងអនាថា

ក្មេងគ្មានឪពុកម្តាយ ក្មេងដែលរងគ្រោះដោយការជួញដូរជាច្រើនពាន់នាក់ទទួលបានការអប់រំ អាហារបំប៉នសុខភាពកាយនិងផ្លូវចិត្តឡើងវិញ។

ភាពកំព្រានិងការរើសអើងនៅក្នុងសង្គម ការចាត់ថ្នាក់ វាយតម្លៃ រើសអើង តាំងពីទើបនឹងកើត ការបោះបង់ចោល ការជួញដូរនិងការរំលោភបំពារបំពានដោយពាក្យសម្តី លើរាងកាយ អំពើហិង្សានានា ការបែកបាក់បងប្អូនម្តាយឪពុក មិនត្រឹមតែនាំមកនូវជំងឺតម្កាត់ ផ្នែករាងកាយសតិបញ្ញាប៉ុណ្ណោះទេ គឺថែមទាំងបង្កាប់ផ្តល់មកជាមួយនូវស្រមោលអន្ទោលនៃភាពអស់សង្ឃឹម បាក់ស្បាត ភាពថប់បារម្ភ ភ័យព្រួយការមិនជឿលើខ្លួនឯង តួយ៉ាងដូចជាអាមីនដែលក្នុងមួយជីវិតរបស់នាង ទោះបីជានាងជាមនុស្សស្លូតត្រង់ ស្មោះស្ម័គ្រ ទៀងត្រង់មិនលោភលន់ តែនាងមិនដែលមានសេចក្តីសុខផ្លូវចិត្តម្តងណាឡើយ ។

ប្រមាណជា៧ឆ្នាំក្រោយមកទៀត ម៉ាចបានមករកខ្ញុំដល់មជ្ឈមណ្ឌលដែលខ្ញុំធ្វើការ។

នៅព្រលប់នោះ ខ្ញុំកំពុងបិទកុំព្យូទ័ររៀបចំនឹងទៅផ្ទះវិញ តែអ្នកយាមបាននាំវាចូលមក។

រូបរាងរបស់វា បានធ្វើឱ្យខ្ញុំដឹងច្បាស់ថា វាគ្មានលុយកាក់ គ្មានអ្វីៗហំហានដូចកាលពីនៅជាមួយភរិយារបស់វានោះឡើយ។

វាប្រហែលជាអាចត្រូវស្រីៗរូបស្រស់ទាំងអស់នោះបោកប្រាស់អស់លុយ ហើយក៏បណ្តេញចេញ ឬមួយក៏សភាពទ្រុស្តក្បត់របស់វានៅក្នុងសង្គម បានផ្តល់មកឱ្យវានូវលទ្ធផលបាចអង្កាមបញ្ច្រាសខ្យល់ ដែលខ្ញុំបានឃើញដោយភ្នែកស្រស់នៅថ្ងៃនេះ។

ដូចស្មានមែន វាបានមកយំយែក ហើយរំឭករឿងអតីតកាលជាច្រើនជាមួយខ្ញុំ សុំឱ្យខ្ញុំកំដរវាផឹក។

ដោយចាត់ទុកថា ជាមនុស្សស្គាល់គ្នា ខ្ញុំព្រមអង្គុយស្តាប់វានិយាយ។ ចុងបញ្ចប់វាបានសារភាពថា វាមានជំងឺធ្ងន់ធ្ងរហើយក៏ត្រូវការ ការដោះដូរបរិច្ចាគសរីរាង្គ ព្រមទាំងត្រូវការជំនួយពីខ្ញុំសម្រាប់ការរះកាត់បន្តជីវិត។

វាបានហាសុំខ្ញុំត្រង់ៗឱ្យខ្ញុំបរិច្ចាគក្រលៀនដល់វា ដូចកាលដែលខ្ញុំបានត្រៀមធ្វើសម្រាប់អាមីន។ ពួកវាទាំងពីរសុទ្ធតែជាប្អូនរបស់ខ្ញុំ ប៉ុន្តែម្នាក់បានបង្រៀនខ្ញុំឱ្យស្គាល់នូវអ្វីទៅដែលហៅថាសភាពអស់សង្ឃឹម និងការឈឺចាប់ស្ងប់ស្ងាត់ ដែលខ្ញុំមិនអាចជួយនាងបានទាន់ពេល ងាកមកម្នាក់ទៀតនេះជាប្រភេទ មនុស្សដែលមានតែសេចក្តីស្រេកឃ្លាន យ៉ាងកក្រើករំពើក និងភាពទ្រុស្តក្បត់ចិត្ត។

ខ្ញុំគ្មានទឹកចិត្តឯណា នឹងបោះដៃទៅជួយវាសាជាថ្មីទៀតនោះឡើយ។

ខ្ញុំបានទៅជួបវានៅថ្ងៃបន្ទាប់ហើយប្រាប់វាថា ៖

«ដោយសារយើងធ្លាប់ស្គាល់គ្នា ជាមនុស្សនៅភូមិជាមួយគ្នា យើងក៏ជាក្មេងដើងចាបដូចគ្នា លុយមួយចំនួននេះឯងយកទៅមើលខ្លួន ហើយរកវិធីរបស់ឯងក្នុងការបន្តរស់រានមានជីវិតតទៅទៀតចុះ! បងប្រុសរបស់ឯងកាលពីអតីតកាល អាម៉ឺនវាបានស្លាប់បាត់យូរហើយ គឺតាំងពីថ្ងៃដែលឯងប្រើមនុស្សឱ្យមកវាយដំច្រំធាក់វា បងប្រុសរបស់ឯងគ្មានឱកាសនៅរស់បន្តដល់ពេលនេះ ដើម្បីផ្ដល់ក្រលៀនគាត់ឱ្យមកឯងទេ សោកស្ដាយផង!»

ខ្ញុំបានចាកចេញពីវា ហើយរៀនធ្វើជាមនុស្សចិត្តដាច់ «ឃើញស្លាប់ក៏មិនជួយ»។

នេះមិនរាប់ថា ជាការសងសឹកទៅលើមនុស្សដែលធ្លាប់ធ្វើអាក្រក់ចំពោះខ្ញុំនោះទេ ព្រោះខ្ញុំបានបំភ្លេចចោលនូវគំនុំ ការឈឺចាប់ផងទាំងពួងអស់ហើយ។ ការបដិសេធរបស់ខ្ញុំនៅពេលនេះ គឺជាការគោរពខ្លួនឯង ឱ្យតម្លៃខ្លួនឯងសំខាន់ជាងតម្រូវការរបស់មនុស្សចោលម្សៀតដូចវា ដែលកាលពីពេលមួយនោះខ្ញុំព្រោះជឿវាថា វាសមនឹងអាមីនជាងខ្ញុំ បានជាខ្ញុំល្ងង់ខ្លៅប្រគល់នាងឱ្យវាបំផ្លាញ។

ខ្ញុំបានស្បថនៅក្រោយថ្ងៃដែលខ្ញុំបានបាត់បង់មនុស្សខ្ញុំស្រលាញ់ថា តទៅមុខខ្ញុំមិនធ្វើអ្វីមួយខុសឆ្គងចំពោះខ្លួនឯងដូចកាលពីអតីតកាលទៀតទេ នៅក្នុងកញ្ចក់ ខ្ញុំនឹងមើលឃើញខ្លួនឯងមានតម្លៃ ព្រោះថា ដោយសារតែការមើលខ្លួនឯងមិនមានតម្លៃនោះហើយ បានជាខ្ញុំព្រមលះបង់នាងទៅឱ្យគេ ដោយសារតែការមើលឃើញខ្លួនឯងមិនស័ក្ដិសមនឹងសាមីនហ្នឹងហើយបានជាត្រូវធ្វើឱ្យនាងអស់សង្ឃឹមនិងបាក់ទឹកចិត្ត ដោយសារតែការមើលខ្លួនឯងឃើញទាបជាងអ្នកដទៃហ្នឹងហើយ បានជាខ្ញុំមិនអាចជួយអ្វីបាន រហូតដល់អាមីនហួសពេល។

ក្រោយពេលអានរឿងរបស់ខ្ញុំនេះចប់ សូមគ្រប់គ្នារៀន ឬបង្កើនការឱ្យតម្លៃខ្លួនឯងមុនពេលឈានទៅជួយជ្រោមជ្រែងការពារមនុស្សដែលពិតជាត្រូវការជំនួយពីយើង។

ខ្ញុំត្រូវតែថែទាំខ្លួនឯង ឱ្យមានសុខភាពរឹងមាំ ដើម្បីបន្តរស់នៅបានវែងឆ្ងាយ មើលឃើញក្មេងៗកម្សត់ជាច្រើនទៀត អាចផ្លាស់ប្ដូរខ្លួនគេ ពីជំងឺផ្លូវចិត្ត និងការបាក់ទឹកចិត្តរ៉ាំរ៉ៃនៅក្រោមស្រមោលនៃភាពកំព្រាឯកោ មកជាមនុស្សរឹងមាំ មានតម្លៃនៅក្នុងសង្គមជាតិ។

«បងឯងបានឈ្នះហើយក្នុងរឿងនេះ តែកុំបានចិត្តពេក! មុននឹងក្រោយទេមនុស្សបោះប្អូនចោលដូចបងឯង!»

នេះជាពាក្យខ្លីដែលម៉ាចផ្ញើមកខ្ញុំ។ វាមិនចម្លែកអ្វីទាំងអស់សម្រាប់មនុស្សធុននេះនៅក្នុងសង្គមក្លែងក្លាយបច្ចុប្បន្ន។

ចូរគិតថា វាជារឿងសាមញ្ញដែលយើង នៅមិននៅធ្លាប់បានលះបង់ និងជួយជ្រោងដោយសុទ្ធចិត្តទៅលើមនុស្សជំពូកនេះ។

ពិតណាស់ដែលពីដំបូងៗ អារម្មណ៍ថាក្បត់ រមិលគុណ នឹងធ្វើឱ្យយើងស្តាយចិត្ត  ខឹង ខ្មាសអៀន និងខូចចិត្តខ្លាំង ជួនវាថែមទាំង អាចធ្វើឱ្យយើងដាក់សំណួរធ្ងន់ៗលើខ្លួនឯងថា ល្ងង់ពេក ចិត្តល្អជ្រុល ឬអន់ជាងពួកគេបានជាគេបោកប្រាស់បាន?

តែពេលនេះ ខ្ញុំមិនបន្ទោសខ្លួនឯងទេ! មិនថាមានអ្វីកើតឡើងក៏ដោយ វាមិនដែលជាកំហុសរបស់យើង ដែលត្រូវបានអ្នកណាម្នាក់មកកេងចំណេញទ្រុស្ត បោកឡើយ។ ការឈឺចាប់នោះ មុននឹងក្រោយគង់តែមានពេលវេលាជាសះស្បើយវិញ។ ដកដង្ហើមវែងៗហើយខ្ញុំទទួលយកថា អ្វីៗជាបទពិសោធន៍ ចាំបាច់អីយើង ទៅខ្ជះខ្ជាយពេលវេលាក្នុងការប្រយុទ្ធប្រឆាំង ឬកែប្រែអ្វីមួយដែលដឹងស្រេចថា មិនអាចផ្លាស់ប្តូរបាន?

ចរិតមនុស្ស អាចប្តូរដោយសារទម្លាប់កែខ្លួននិងការសិក្សា តែសារជាតិមនុស្ស ពិបាកណាស់ក្នុងការប្រើបេះដូងយើងទៅវិនិយោគជាមួយ។

កាលពីមុន ពេលវាចេញទៅអូស្ត្រាលី ហើយសរសេរសំបុត្រមកប្រាប់ខ្ញុំដែលថា ខឹងខ្ញុំប្រគល់អាមីនទៅឱ្យអ្នកមានម្នាក់នោះ ខ្ញុំពិបាកចិត្តសោកស្តាយខ្លាចបាត់បង់ប្អូនម្នាក់នេះ។ ខ្ញុំចង់ពន្យល់ចង់បកស្រាយម៉ាច  ប៉ុន្តែឆ្លងកាត់រឿងជាច្រើន  ពាក្យផ្ញើមករបស់វាលើកនេះ គ្មានតម្លៃអ្វីក្នុងការចងចាំរបស់ខ្ញុំផង កុំថាឡើយមកឱ្យប៉ះទង្គិចបេះដូងខ្ញុំបានទៀត។

ជីវិតទៅមុខ ខ្ញុំត្រូវមានកន្លែងទំនេរសម្រាប់ទទួលយកសុភមង្គល ដូច្នេះប្រសិនបើបេះដូងនៅតែចងចាំមនុស្សគម្រក់ៗដែលបង្កតែការឈឺចាប់ ម្តេចយើងមិនសម្រេចចិត្តឱ្យអ្វីៗរលុបទៅតាមពេលវេលាទៅ?

រឿងចាស់ក្នុងជីវិតយើងម្នាក់ៗ មិនអាចរលាយបាត់បានដោយខ្លួនឯងទេ ដូច្នេះហើយខ្ញុំ ត្រូវធ្វើការប្តេជ្ញាចិត្តដើម្បីឱ្យវាបាត់ទៅតាមរយៈ «លែងរវល់ លែងដឹងឮ និងលែងពាក់ព័ន្ធ»។

គ្រប់គ្នាមិនអាចរស់បានលើស១០០ឆ្នាំទេ ថ្ងៃណាមួយ ម៉ឺននិងសាមីន បានស្លាប់បាត់ទៅនៅក្នុងរឿងនិទានរបស់ពួកគេ ហើយពួកគេបានជួបគ្នានៅទីស្ងប់មួយ។

នៅលើផែនដីនេះ នៅសល់តែអំពើល្អនិងការបរិច្ចាគដែលពួកគេបានបន្សល់ទុក បើទោះអ្នកដទៃពេបជ្រាយរិះគន់ថា «ល្ងង់ ឆ្កួត ជោរ» «មិនដែលមាន» ឬ«ខុសគេ» ខ្ញុំមិនរវល់នឹងមនុស្សចាត់ថ្នាក់វិនិច្ឆ័យទាំងនោះទ្បើយ។

សូមអរគុណដែលបានអានដល់ចប់

សូមទុកពាក្យមួយឃ្លាស្រង់ចេញពីប្រលោមលោកនេះដែលអ្នកស្រលាញ់ពេញចិត្ត